រាជបណ្ឌិត្យសភាកម្ពុជា

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## - ភាគទី៦ - វគ្គទី១

អត្ថបទចងក្រងដោយៈ លោកស្រី ស៊ិន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



ពិធីសម្ពោធវិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១[1]

[1] https://sopheak.wordpress.com/2015/11/30

## ៦-ដំណើរការនៃពិធីសម្ពោធ

### ៦-១-ការសម្តែងឱ្យឃើញអំពីមិត្តភាពបារាំង-ខ្មែរ

ផ្អែកលើបណ្ណសារស្តីពី «បុន្យឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ (ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨)»[2] នោះ ការសម្តែងឱ្យឃើញអំពីមិត្តភាពបារាំង-ខ្មែរមានខ្លឹមសារដើមទាំងស្រុង និងការកែសម្រួលមួយចំនួនដូចខាងក្រោមៈ

*ការធ្វើបុណ្យឆ្លងវិមានសម្រាប់រំឭកគុណ ដល់អស់ជាតិបារាំងសែស និងជាតិខេមរៈដែលទទួលអនិច្ចកម្មជួស«ព្រះមហានគរជាមាតា»[3]នោះ សម្រេចធ្វើបុណ្យនៅថ្ងៃ៧កើត ខែផល្គុន ឆ្នាំជូតឆស័ក ត្រូវគ្នានឹងថ្ងៃទី១ ខែមីនា ឆ្នាំ១៩២៥។ ថ្ងៃនេះនឹងកត់ចុះជាណាំក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតីទុកជាថ្ងៃធ្វើពិធីបុណ្យមួយយ៉ាងធំសំខាន់ ពិតមែនតែក្រុងកម្ពុជា។ស្រុកមួយដែលមានធ្វើបុណ្យយ៉ាងល្អប្លែក។។*

*ក្នុងខណៈនេះ នៅក្នុងក្រុងភ្នំពេញ បានដោតទង់ជ័យ និងតាក់តែងលំអផ្សេងអស់ពីចិត្ត ហើយថ្ងៃសោតក៏រះល្អ ហាក់ដូចជាជួយឈឺឆ្អាលធ្វើបុណ្យនេះឱ្យបានស្រួលតាមការ។ នេះដូចជាលោកឡឺវេស៊ីដង់ សុប៉េរីយ៉ើរ បូឌូវាំង(Baudoin) ជាមែន គឺនៅពេលដែលមេឃភ្លឺថ្ពុះល្អ នោះរូបដែលបានសាងទុកនោះ លុះបានបកសំពត់ដែលគ្របចេញហើយ ក៏រូបនោះលេចឡើងនៅកណ្តាលចំណោមមនុស្សច្រើនពាន់ ដែលមានចិត្តចង់មើលរូបនោះឱ្យខាងតែឃើញ។ ក្នុងចំណោមមនុស្សទាំងអស់នោះមានមនុស្សជាច្រើនឈរអន្ទុយជ្រៀតគ្នាចាំមើលរូបនោះតាំងពីព្រលឹមស្រាង។។ តាមដែលមនុស្សយើងនៅចាំបាននោះ តាំងពីដើមរៀងមកពុំដែលមានឃើញមនុស្សច្រើនអនេកនៅក្នុង«ដីជុំនុំក្រុងកម្ពុជា»[4]ដូច្នេះឡើយ ហើយខាង*

---

[2] បុន្យឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នកដែលទទួលអនិច្ចកម្មក្នុងចំបាំងធំ (ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៧២-៧៣។

[3] ប្រទេសកម្ពុជាដែលបាននៅក្រោមអាណាព្យាបាលបារាំងនោះ បានហៅប្រទេសបារាំងថា ព្រះមហានគរជាមាតា ដែលត្រូវនឹងពាក្យ«មាតុធានី»សព្វថ្ងៃនេះ។ ជាពាក្យបារាំងហៅថា Métropole។

[4] ដីជុំនុំក្រុងកម្ពុជា គឺរាជធានីភ្នំពេញ។

*ចំណែកលោកអធិបតីរាជការប្រូតិចតូរ៉ា[5] ដែលមានចិត្តប្រាថ្នាចង់ឱ្យបុណ្យនេះធំថ្កើងរុងរឿង លើសបុណ្យពីមុនៗមកនោះ លោកក៏ខិតខំហៅរកមនុស្សគ្រប់ភាសាឱ្យមកជួយក្នុងបុណ្យនេះ ដើម្បីឱ្យសេចក្ដីរុងរឿងកាន់តែខ្ពង់ខ្ពស់ឡើងទៀត។ នោះមានកងសេនាទាហ៊ានបញ្ជូនមកពីស្រុកព្រៃនគរ សម្រាប់តែក្នុងការនេះឯង ដើម្បីនឹងតំណាងកងទ័ព ក្នុងពិធីបុណ្យនេះ១ ហើយមួយទៀតដើម្បីនឹងលើកបុណ្យនេះឱ្យខ្ពង់ខ្ពស់ ដោយមានសេនាទាហានមកជួយផង។ ឯសេនាទាហានគ្រប់ក្រុមទាំងអស់ ក៏បានចាត់តំណាងមកតែរៀងខ្លួន គឺក្រុមទាហានបារាំងសែសដើងគោកមានទង់ជ័យ និងភ្លេងរបស់អុងស៊ីយាមកូឡូនីញ៉ាល់ជាតំណាង[6] ក្រុមកាំភ្លើងធំមានទង់ជ័យជាតំណាង ហើយមានទាំងរទេះឡានបាញ់កាំភ្លើងមីត្រៃយើស៍[7] មានរទេះសម្រាប់ឡើងលុក មានយន្តហោះ ហើយមានទាំងទាហានជើងទឹក១ក្រុមតូចផង។*

*ហើយមានពួកបម្រើនៃបណ្ដាពស្ត្រគ្រប់ភាសា ដែលមាននៅក្នុងស្រុក ស្លៀកពាក់តាមជាតិរបស់ខ្លួនទីទៃៗ ក៏បានមកជួយក្នុងពិធីង៉ាន(បុណ្យ)នេះ នាំឱ្យមានសេចក្ដីសប្បាយរីករាយជាប្លែកចម្លែកជាងពីមុនៗមក។*

**៦-២-រូបវិមាន**

ក្រុមកុំមីតេ( Comité )[8] ដែលទទួលត្រួតមើលការកសាងវិមាននេះ បានព្រមព្រៀងនឹងលោកអធិបតីរាជការប្រូតិកតូរ៉ា ក៏បានជ្រើសរើសដីមួយកន្លែង នៅជ្រុងផ្លូវធ្លាធំឈ្មោះបូលើវ៉ា[9]សំពោរនិងមីស (Miche)។ ក្នុងសម័យនេះ ទីដីនោះពុំបាននៅចំកណ្ដាលក្រុងទេ ក៏ប៉ុន្តែគង់មានមនុស្សទៅមកជាញឹកញាប់គ្រាន់បើដែរ អស់ទាំងមនុស្សនៅក្រុងភ្នំពេញ អស់ទាំងអ្នកប្រទេសក្រៅ ដែលតែងដើរព័ទ្ធជុំវិញក្រុងភ្នំពេញជាកម្សាន្តក្រោយម៉ោង៥រសៀលនោះត្រូវតែដើរកាត់នៅមុខវិមានរូបនេះដែលសាងទុកនៅកណ្ដាល

---

[5] ប្រូតិចតូរ៉ា (Protectorat) គឺរបបអាណាព្យាបាល។

[6] ក្រុមទាហាន«អុងស៊ីយាមកូឡូនីញ៉ាល់» (Onzième Coloniale) គឺទាហានអាណានិគម អង្គភាពទី១១។

[7] មីត្រៃយើស៍(Mitrailleuse) គឺកាំភ្លើងយន្តធំបាញ់ជាបន្តច្រើនគ្រាប់បាន។

[8] ក្រុមកុំមីតេ( Comité ) គឺគណៈកម្មាធិការ។

[9] បូលើវ៉ា( Boulevard ) គឺមហាវិថី។

សួន១។ សព្វថ្ងៃសួននេះរៀបចំពុំទាន់ហើយស្រេចទេ តែរៀបចំហើយវេលាណា មុខជាល្អសំខាន់ជាងសួនច្បារឯទៀត ដែលមាននៅក្នុងទីក្រុងទាំងប៉ុន្មាន។




វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

បើរៀបឱ្យស្រឡះរួចហើយនោះ ការដែលជាងចម្លាក់ឌូក្វាំង( Ducoing) បានសាងក៏ចោលស្រមោលលេចឡើងជាសម្បើម មានជើងកុះទ្រពីក្រោមជាមាំមួន។ បើឈរពិនិត្យមើលពីមុខរូបនោះទៅនោះឃើញថាពុំមែនជារបស់ទាំងដុលនៅស្ងៀមព្រងើយនោះទេ គឺមើលទៅឃើញវិស័យដូចជារូបរស់ប្រាកដជាដូចរស់ពិតមែន។ តាមភ្នែកយើងសំឡឹងទៅឃើញ ហាក់ដូចជារូបនោះនិយាយចរចាតាមចិត្តគំនិតយើង ក៏ឃើញថារូបនោះនិយាយដែរ។ ឯរបស់នេះ គឺជាតឹកតាងសេចក្តីរួបរួមបារាំងសែសនិងខ្មែរនិងសេចក្តីដែលជាតិខ្មែរមានចិត្តសង្រួម[10]កតញ្ញូដល់បុគ្គលដែលស្លាប់ទៅ របស់នេះបង្ហាញឱ្យយើងឃើញទាហានបារាំងសែស១នាក់ នាំទាហានខ្មែរ១នាក់មកស្រុកវិញ។ ឯអ្នកទាំងនេះ បានបេះប្រឡេះយកស្លឹកកន្ទួតជាច្រើននៅក្នុងគ្រាចម្បាំងនេះ។ ឯទាហានបារាំងក៏យកដៃឆ្វេងដាក់លើស្មាទាហានខ្មែរ នោះយើងមើលទៅឃើញថា ទាហានបារាំងសែសនោះជាអ្នកនាំផ្លូវ ហើយជាអ្នកទំនុកបម្រុងផង។ ឯបណ្តាជនស្រុកអាយមានសេចក្តីរំជួលជាខ្លាំង ដោយឃើញទាហានទាំង២នាក់ នោះមុនដំបូងក៏សង្រួមរូបកាយរួចក៏ដើរចូលទៅជិត មានស្រីខ្លះហុចដៃទៅឱ្យទាហាននោះ ស្រីខ្លះលើកផ្កាទៅឱ្យ ហើយមានស្រីខ្លះទៀតលើកកូនទៅបង្ហាញ។ ហើយមានបណ្តាជន១ពួកសុទ្ធតែប្រុស យកស្វេតឆត្រទៅបាំងឱ្យទាហានទាំង២នាក់ដែលមានជ័យជម្នះត្រឡប់វិលមកវិញនោះ។

ឯជ្រុងខាងលិចដែលជាមុខវិមាននោះ ឆ្លាក់ជាអក្សរមាស សេចក្តីដូចមានខាងក្រោមនេះ។

**«ជូនបុគ្គលដែលអនិច្ចកម្ម ក្នុងចំបាំងធំ»**

ឯជ្រុងខាងកើតមានអក្សរច្រើនបន្ទាត់ ដូចមានខាងក្រោយនេះ។

វិមាននេះជាស្នាដៃជាងចម្លាក់(ប៉ូលឌូក្វាំង) ហើយដែលរាជការអាណាព្យាបាល ក្រុងកម្ពុជានិងរាជការក្រុមមឿងក្រុងភ្នំពេញបានសាងទុក តាមគំនិតលោកឡឺរេស៊ីដង់ សុប៉េរីយ៉ើរ បូដូវាំង។

( សូមរង់ចាំអានភាគបន្ត...)

---

[10] សង្រួម(កិ) ប្រយ័ត្នមិនឱ្យអារម្មណ៍អាក្រក់ចូលមកបាន វនានុក្រមខ្មែរពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៧, ទំព័រ ១២៤៣។